# តារាងស្ដីពីព័ត៌មានរបស់គម្រោង

លេខPIP : 179

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ទប់ស្កាត់ការដាក់ទណ្ឌកម្មដល់ រាងកាយ និង ផ្លូវចិត្តកុមារ

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/05/15

កាលបរិច្ឆេទបញ្ចប់គម្រោង 31/12/18

៣. ចំណាយគម្រោងសរុប $99,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកិច្ចការនារី

RESPONSIBLE UNIT

អង្គភាពទទួលខុសត្រូវ នាយកដ្ឋានស្ត្រី និងអប់រំ

៥. ស្ថានភាពគម្រោង គម្រោងដែលបានបញ្ចប់

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

អភិបាលកិច្ច និងរដ្ឋបាល Governance and Administration

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

ក្រចេះ, កំពង់ឆ្នាំង, សៀមរាប, កោះកុង, ត្បូងឃ្មុំ , កំពង់ចាម, ព្រះវិហារ, ពោធិ៍សាត់, រាជធានីភ្នំពេញ, ស្ទឹងត្រែង, ព្រៃវែង,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

ស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការអភិវឌ្ឍន៍ចាត់អាទិភាពលើការទប់ស្កាត់អំពើហិង្សា និងការរំលោភបំពានលើកុមារដោយបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិ កុមារ។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

១.គម្រោងនេះអនុវត្តន៍ដោយមានការសហការចូលរួមពី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនិតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងព័ត៌មាន ក្រសួងធម្មការ និងសាសនា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ អង្គការ Save Children មូលនិធិអង្គការសហប្រជាជាតិ ដើម្បីកុមារ(UNICEF) អង្គការវិនិយោគដើម្បីដើម្បីកុមារ និងសង្គម (ICS) និងអង្គការសេវាសង្គមកិច្ចកម្ពុជា(SSC)។

២. គម្រោងនេះអនុវត្តន៍ដោយមានការចូលរួមពីអង្គការដៃគូរបស់អង្គការSave Children មន្ទីរ និងការិយាល័យ កិច្ចការនារី អាជ្ញាធរឃុំ ភូមិ និងអ្នកស្ម័គ្រចិត្តភូមិនៅថ្នាក់ក្រោមជាតិ។

៣. រៀបចំឱ្យមានយុទ្ធសាស្ត្រ និងឧបករណ៍សម្រាប់ពង្រឹងសមត្ថភាពដល់អ្នកពាក់ព័ន្ធ និងធ្វើការផ្សព្វផ្សាយដល់ សហគមន៍។

៤. មានការវាស់ស្ទង់ការយល់ដឹងរបស់ក្រុមគោលដៅនៅសហគមន៍ និងធ្វើការផ្សព្វផ្សាយ។

៥. គាំទ្រដល់ថ្នាក់ក្រោមជាតិក្នុងការអនុវត្តគម្រោង

៦. មានការពិនិត្យតាមដាន និងវាយតម្លៃប្រសិទ្ធភាពគម្រោង

៧. មានការចុះកិច្ចព្រមព្រៀង និងផ្តល់ថវិកា១ឆ្នាំម្តង

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវថ្នាក់ជាតិ ស្តីពីអំពោះហិង្សាលើកុមារ របស់ក្រសួងកិច្ចការនារី នៅក្នុងឆ្នាំ២០១៤ (CVACS)។ នៅក្នុងការសិក្សានេះ បានធ្វើការសាកសួរកុមារ និងប្រជាជនវ័យក្មេងចំនួន ២.៣៧៦នាក់ ដែលមានអាយុចន្លោះពី ១៣ នៅ ២៤ឆ្នាំទូទាំងប្រទេស អំពី បទពិសោធន៍របស់ពួកគេទាក់ទងអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទមុនពេលអាយុ ១៨ឆ្នាំ។

របបគំហើញ CVACS បានគូសបញ្ជាក់ថា៖

- កុមារកម្ពុជាជាង ៥០% នៃកុមារកម្ពុជាទាំងអស់ បានទទួលរងការរំលោភបំពានផ្លូវកាយ។ កុមារទាំងនោះ រំលឹកពីការដែលត្រូវគេដាល់ ទាត់ វាយនឹងរំពាត់ ឬវាយនឹងរបស់អ្វីមួយ។
- កុមារកម្ពុជាចំនួន មួយភាគបួន ទទួលរងការរំលោភបំពានផ្លូវចិត្ត ដោយឪពុកម្តាយ អ្នកថែទាំ ឬសាច់ញាតិពេញវ័យដទៃទៀត។
- ឪពុកម្តាយមែងតែងជាអ្នកដែលប្រព្រឹត្តអំពើរំលោភបំពាន៖ កុមារភាគច្រើនបានរាយការណ៍ឱ្យដឹងថា ឪពុក ឬម្តាយគឺជាអ្នកប្រព្រឹត្តហេតុការណ៍អំពើហិង្សាផ្លូវកាយដំបូងគេបង្អស់ ជាពិសេសគឺម្តាយ។ ម្តាយក៏ជាអ្នកដែលត្រូវបានដកស្រង់ញឹកញាប់ផងដែរថាជាជនដែលបានប្រព្រឹត្តហេតុការណ៍អំពើហិង្សាផ្លូវកាយដំបូងគេបង្អស់។
- ជាទូទៅ កុមារប្រឈមទៅនឹងអំពើហិង្សានៅឯផ្ទះ ៖ ក្នុងចំណោមកុមារដែលមានអាយុចន្លោះពី ១៣ ដល់ ១៧ឆ្នាំ ដែលបានដឹងលឺអំពីអំពើហិង្សាផ្លូវកាយនៅឯផ្ទះ ដែលក្នុងនោះ ៣៧,៤% ជាកុមារី និង ៣៤,៧% ជាកុមារា បានរាយការណ៍ឱ្យដឹងថា ពួកគេបានឃើញអំពើហិង្សាផ្លូវកាយ ក្នុងរយៈពេល ១២ខែចុងក្រោយ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

អ្នកដែលទទួលផលផ្ទាល់ ៖ ក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ អាជ្ញាធរមូលដ្ឋាន ឪពុកម្តាយ អ្នកថែទាំ អ្នកដែលនឹងក្លាយជាឪពុកម្តាយឆាប់ៗ (ស្រីមានផ្ទៃពោះ និងដៃគូ) អ្នកដែលនឹងក្លាយជាឪពុកម្តាយនាពេលអនាគត (យុវវ័យ)។ អ្នកដែលទទួលផលមិនផ្ទាល់ ៖ កុមារ និង ប្រជាជនក្នុងសហគមន៍

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | ត្រូវបានបញ្ចប់ |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

ការចិញ្ចឹមកូនបែបវិជ្ជមាន ដើរតួនាទីមួយដ៏សំខាន់ក្នុងការបង្ការអំពើហិង្សា និងជាចំណុចស្នូលនៃការអភិវឌ្ឍន៍ដ៏ល្អ ប្រសើររបស់កុមារ។ ជីវិតគ្រួសារមួយប្រកបដោយស្នេហភាព និងមានសុវត្ថិភាព រាប់បញ្ចូលទំនាក់ទំនងវិជ្ជមានជាមួយ ឪពុកម្តាយ ឬ អ្នកថែទាំ មានសារៈសំខាន់ខ្លាំងណាស់ដើម្បីឱ្យកុមារទទួលបានជោគជ័យនៅឯសាលារៀន ដើម្បីឱ្យ មានទំនាក់ទំនងល្អជាមួយអ្នកដទៃ និងដើម្បីឱ្យក្លាយជាមនុស្សពេញវ័យដែលមាន ផលិតភាពខ្ពស់ក្នុងសង្គមនៅពេល អនាគតយូរអង្វែងខាងមុខ។ ការចិញ្ចឹមកូនបែបវិជ្ជមាន អាចទប់ស្កាត់មិនឱ្យកុមារទទួលរង ផលវិបាកបណ្តាលពីការ លំបាក និងភាពអវិជ្ជមានដទៃទៀតក្នុងជីវិត រាប់បញ្ចូលភាពក្រីក្រ និងអំពើហិង្សា។ ចំណុចនេះគូសបញ្ជាក់អំពី សារៈសំខាន់នៃការផ្តល់ឱ្យឪពុកម្តាយ និងអ្នកថែទាំនូវកិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនបែបវិជ្ជមាន។

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែល ទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

ការអភិវឌ្ឍ និងការអនុវត្តយុទ្ធសាស្ត្រផ្លាស់ប្តូរការប្រព្រឹត្ត និងសង្គមពហុវិស័យគ្រប់ជ្រុងជ្រោយមួយ ដើម្បីឆ្លើយតបទៅ នឹងទម្លាប់សង្គម និងវប្បធម៌ដែលលើកកម្ពស់ និងចាត់ទុកអំពើហិង្សាលើកុមារថាជាអំពើស្របច្បាប់។ ឪពុកម្តាយ និងអ្នកថែទាំកុមារ ចូលរួមយ៉ាងសកម្មក្នុងការទទួលយកចំណេះដឹង ជំនាញ និងបទពិសោធន៍ នៃការចិញ្ចឹមកូន បែបវិជ្ជមាន និងអនុវត្តជាមួយកូនៗ នៅឯផ្ទះ។ បន្ថែមពីនេះទៀត កម្មវិធីភាគច្រើនផ្តោតលើអ្នកថែទាំជាស្ត្រី (ការទទួលខុសត្រូវរបស់ម្តាយ) ដែលជាហេតុនាំឱ្យមានការពង្រឹងបន្ថែមទៅលើតួនាទីយេនឌ័របែបប្រពៃណី និងលើកកម្ពស់ការចូលរួមរបស់ឪពុក (ការទទួលខុសត្រូវរបស់ឪពុក) អោយមានទំនាក់ទំនងទៅនឹងលទ្ធភាពវិជ្ជមានរបស់កុមារ និងការទទួលខុសត្រូវរបស់កុមារ ក្នុងការជួយកាត់បន្ថយកម្រិតនៃវិបត្តិតានតឹងក្នុងការចិញ្ចឹមកូនរបស់ម្តាយ និងអ្នកថែទាំដទៃទៀត។ នៅក្នុងវិស័យស្នូលនឹងដោះស្រាយហានិភ័យដែលមានលក្ខណៈសំខាន់បំផុត និងកត្តាការពារ ដែលគេដឹងថាអាចទប់ស្កាត់អំពើហិង្សាលើកុមារបាន និងអាចព្យាករណ៍អំពីការចិញ្ចឹមកូនបែបវិជ្ជមាន។ បញ្ហាយេនឌ័រ និងពិការភាព នឹងត្រូវបានយកមកបញ្ចូលទៅក្នុងគ្រប់វិស័យទាំងអស់ ក្នុងទម្រង់ជាបញ្ហា ដែលមានលក្ខណៈប្រទាក់ ក្រឡាគ្នា ហើយកញ្ចប់ឧបករណ៍នេះ នឹងបញ្ចូលនូវវិធីសាស្ត្រ វដ្តជីវិតមួយដែលផ្តល់នូវព័ត៌មានអំពីការចិញ្ចឹមកូន ដែលមានភាពជាក់លាក់ទៅតាមអាយុ សម្រាប់កុមារា និងកុមារី អាយុក្រោម ៣ឆ្នាំ អាយុ ៣-៥ឆ្នាំ អាយុ ៦-១២ឆ្នាំ និងអាយុ ១៣-១៨ឆ្នាំ។

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

ក្រុមជំនាញមកពីក្រសួង នៅមានកម្រិត ដូច្នេះហើយអង្គការ Save the children និង UNICEF បានជួយផ្ដល់ជាបច្ចេកទេសដោយផ្ទាល់ និងតាមរយៈទីប្រឹក្សាជាតិ ដើម្បីជំនាញសម្របសម្រួល ការចងក្រងកូនសៀវភៅមាន និងការបង្កើតផែនការយុទ្ធសាស្ត្រ។

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបញ្ហាប្រឈមនានា ដែល បណ្ដាលឲ្យមាន ការពន្យាពេលក្នុងការអនុវត្តគម្រោង។)

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

4

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្ដល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្ដានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2017 | | 2018 | 2019 | 2020 | 2021 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2019-2021 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 24.7 | 0.0 | 24.7 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 24.7 | 0.0 | 24.7 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 24.7 | 0.0 | 24.7 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2017 | | 2018 | 2019 | 2020 | 2021 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2019-2021 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | 24.7 | 0.0 | 24.7 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| UNICEF | 24.7 | 0.0 | 24.7 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 24.7 | 0.0 | 24.7 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: